ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៩១ .អនក្រ-បក

# អនុក្រឹត្យ
# ស្តីពី
# អត្តសញ្ញាណកម្មគ្រួសារក្រីក្រ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១១

# សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រងលើការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រនិងការប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីផ្ដល់ទិន្នន័យសម្រាប់ប្រើប្រាស់ក្នុងសកម្មភាពកាត់បន្ថយភាពក្រីក្រ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចខាងក្រោម៖

**អត្តសញ្ញាណកម្មគ្រួសារក្រីក្រ** សំដៅដល់ការកំណត់គ្រួសារក្រីក្រ កម្រិតភាពក្រីក្រ និងអត្រាភាពក្រីក្រតាមតំបន់។

**នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ** សំដៅដល់នីតិវិធីផ្លូវការនៃក្រសួងផែនការសម្រាប់ស្វែងរកគ្រួសារក្រីក្រនិងកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ។

**ចំណាត់ថ្នាក់ភាពក្រីក្រ** សំដៅដល់ការចាត់ថ្នាក់ភាពក្រីក្រជាភាពក្រីក្រកម្រិត១និងកម្រិត២។

**បញ្ជីគ្រួសារក្រីក្រ** សំដៅដល់បញ្ជីរាយឈ្មោះគ្រួសារក្រីក្រកម្រិត១និងកម្រិត២នៅភូមិណាមួយដែលបញ្ជាក់ទទួលស្គាល់ដោយមេឃុំ ចៅសង្កាត់ បន្ទាប់ពីការសម្រេចរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ដោយផ្អែកលើលទ្ធផលនៃការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

**មូលដ្ឋានទិន្នន័យគ្រួសារក្រីក្រ** សំដៅដល់កម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងទិន្នន័យគ្រួសារក្រីក្ររួមទាំងការបញ្ចូល ការចងក្រង ការរក្សាទុក ការបញ្ចេញ និងការផ្ទុកទិន្នន័យដែលត្រូវបានប្រមូលតាមនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

**ព័ត៌មានគ្រួសារក្រីក្រ** សំដៅដល់របាយការណ៍ដែលផលិតចេញពីមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រ។

**ភូមិជនបទ** សំដៅដល់ភូមិទាំងឡាយណាដែលមានភាគរយនៃគ្រួសារប្រកបមុខរបរផ្នែកកសិកម្មចាប់ពី៥០ភាគរយឡើងទៅ។

**ភូមិទីប្រជុំជន** សំដៅដល់ភូមិទាំងឡាយណាដែលមិនមែនជាភូមិជនបទ។

## ជំពូកទី២
## ស្ថាប័នគ្រប់គ្រង

**មាត្រា ៥.-**

ក្រសួងផែនការជាស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងដំណើរការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅព្រះរាជាណាចក្រកម្ពុជា និងធ្វើបច្ចុប្បន្នកម្មទិន្នន័យនិងព័ត៌មានគ្រួសារក្រីក្ររៀងរាល់៣ឆ្នាំម្តង។

**មាត្រា ៦.-**

ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ត្រូវសហការជាមួយនឹងក្រសួងផែនការដើម្បីសម្របសម្រួលនិងអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

**មាត្រា ៧.-**

ក្រសួងផែនការមានភារកិច្ច សម្របសម្រួល តាមដានត្រួតពិនិត្យការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រនិងណែនាំផ្នែកបច្ចេកទេស ដល់ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋានដែលចូលរួមធ្វើការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ។

**មាត្រា ៨.-**

ក្រសួងផែនការត្រូវផ្សព្វផ្សាយព័ត៌មានដល់បណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន អំពីតំបន់ដែលបានអនុវត្តនិងតំបន់ដែលគ្រោងអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

**មាត្រា ៩.-**

ក្នុងករណីមានការស្នើសុំអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្នុងតំបន់ណាមួយដោយក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន ក្រសួងផែនការអាចអនុញ្ញាតឲ្យអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅក្នុងតំបន់នោះ តាមនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ ក្រសួងផែនការត្រូវសម្រេចក្នុងរយៈពេល៤សប្តាហ៍យ៉ាងយូរ បន្ទាប់ពីបានទទួលលិខិតស្នើសុំ។ ទិន្នន័យដែលក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋានណាមួយប្រមូលបាន ត្រូវប្រគល់ជូនក្រសួងផែនការគ្រប់គ្រង។

ក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋានមិនអាចកំណត់អត្តសញ្ញាណគ្រួសារក្រីក្រនៅក្នុងតំបន់ណាដែលមានទិន្នន័យផ្លូវការស្តីពីគ្រួសារក្រីក្រនៅមានសុពលភាព ឬនៅក្នុងតំបន់ណាដែលកំពុងអនុវត្តឬគ្រោងអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្របានឡើយ។

**មាត្រា ១០.-**

ក្នុងករណីដែលក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋានណាមួយត្រូវការប្រមូលទិន្នន័យបន្ថែមផ្សេងទៀតអំពីគ្រួសារក្រីក្រ ស[illegible]ម្មភាព

កាត់បន្ថយភាពក្រីក្រ ដែលទិន្នន័យនោះមិនមាននៅក្នុងបញ្ជីសំណួរសម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្ររបស់ក្រសួងផែនការ ក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋានទាំងនោះត្រូវស៊ុំការអនុញ្ញាតពីក្រសួងផែនការជាលាយលក្ខណ៍អក្សរ។ ក្រសួងផែនការត្រូវសម្រេចក្នុងរយៈពេល៤សប្តាហ៍យ៉ាងយូរ បន្ទាប់ពីបានទទួលលិខិតស្នើសុំ។

## ជំពូកទី៣
## នីតិវិធីនិងលក្ខណៈវិនិច្ឆ័យ

**មាត្រា ១១.-**

ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រនៅព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់ក្រសួងផែនការ។ សម្រាប់ភូមិជនបទនិងភូមិទីប្រជុំជនត្រូវប្រើប្រាស់នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រផ្សេងគ្នា តាមការណែនាំរបស់ក្រសួងផែនការ។

នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងផែនការ។

**មាត្រា ១២.-**

ដើម្បីធានាតម្លាភាពក្នុងការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រនិងភាពសុក្រឹតនៃទិន្នន័យគ្រួសារក្រីក្រ នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រត្រូវអនុលោមតាមគោលការណ៍សំខាន់ៗ ដូចខាងក្រោម៖

ក- ត្រូវអនុវត្តដោយក្រសួងផែនការដោយមានការចូលរួមរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមតំណាងភូមិ។

ខ- ត្រូវជ្រើសរើសដោយអ្នកភូមិនូវក្រុមតំណាងភូមិដែលទទួលខុសត្រូវអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ។

គ- ត្រូវសម្ភាសគ្រួសារដោយប្រើប្រាស់បញ្ជីសំណួរដែលមានលក្ខណៈវិនិច្ឆ័យ ដូចមានកំណត់ក្នុងនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីកំណត់គ្រួសារក្រីក្រប្រកបដោយសមធម៌និងទទួលបានទិន្នន័យដែលអាចប្រៀបធៀបគ្នាបានរវាងគ្រួសារនិងរវាងតំបន់ខុសៗគ្នា។

ឃ- ត្រូវធ្វើការចាត់ថ្នាក់ភាពក្រីក្ររបស់គ្រួសារ តាមរយៈការបូកពិន្ទុផ្អែកលើចម្លើយដែលបានមកពីការសម្ភាសនិងការពិភាក្សាលើស្ថានភាពជាក់ស្តែងរបស់គ្រួសារនីមួយៗ។

ង- ត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់ប្រជាជនក្នុងភូមិនីមួយៗឲ្យចូលរួមក្នុងការផ្តល់មតិយោបល់និងលើកសំណូមពរនានាលើបញ្ជីព្រាងគ្រួសារក្រីក្រ ដោយផ្អែកលើការយល់ដឹងពីស្ថានភាពជាក់ស្តែងរបស់គ្រួសារដែលរស់នៅក្នុងភូមិ។

ច- មានតែក្រុមតំណាងភូមិប៉ុណ្ណោះ ដែលមានសិទ្ធិសម្រេចលើសមាសភាពគ្រួសារក្រីក្រក្នុងបញ្ជីព្រាងគ្រួសារក្រីក្រចុងក្រោយ។

ឆ- ត្រូវមានការបញ្ជាក់ទទួលស្គាល់បញ្ជីគ្រួសារក្រីក្រចុងក្រោយជាផ្លូវការ ដោយមេឃុំ ចៅសង្កាត់បន្ទាប់ពីការសម្រេចរបស់ក្រុមប្រឹក្សាឃុំសង្កាត់។

**មាត្រា ១៣.-**

ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រត្រូវផ្អែកលើការសម្ភាសគ្រួសារដោយប្រើប្រាស់បញ្ជីសំណួរដែលរៀបចំដោយក្រសួងផែនការ។ បញ្ជីសំណួរនេះត្រូវបញ្ចូលសូចនាករវាស់វែងភាពក្រីក្រ ជាអាទិ៍៖

- ស្ថានភាពផ្ទះរួមមាន ដំបូល ជញ្ជាំង ផ្ទៃក្រឡា គុណភាពផ្ទះ(ព្រមទាំងបញ្ជាក់ថាជាកម្មសិទ្ធិផ្ទាល់ឬជួលគេ)
- ទំហំដីលំនៅឋាននិងដីផលិតកម្មកសិកម្មដែលបានកាន់កាប់ដោយស្របច្បាប់
- ប្រភពចំណូលចម្បងដែលបានមកពីការដាំដុះ ឬនេសាទ ឬសកម្មភាពផ្សេងទៀត
- ការចិញ្ចឹមសត្វ(ដូចជាការចិញ្ចឹមត្រីសម្រាប់លក់)
- លទ្ធភាពដោះស្រាយស្បៀងអាហារ
- ចំនួនសមាជិកគ្រួសារដែលរកចំណូលមិនបាន ដោយធៀបនឹងចំនួនសមាជិកសរុប
- សម្ភារៈនិងឧបករណ៍ប្រើប្រាស់
- មធ្យោបាយធ្វើដំណើរ
- បញ្ហាចៃដន្យឬវិបត្តិធ្ងន់ធ្ងរដែលបណ្តាលឲ្យគ្រួសារបាត់បង់ចំណូល ខ្វះខាតម្ហូបអាហារ លក់ទ្រព្យសម្បត្តិ ឬជំពាក់បំណុល
- ចំនួនក្មេងដែលមានអាយុពី៦ឆ្នាំដល់១១ឆ្នាំ ខកខានរៀននៅសាលា និងមូលហេតុ
- ស្ថានភាពដែលធ្វើឲ្យជីវភាពគ្រួសារធ្លាក់ចុះដូចជា មេគ្រួសារ(ប្តីឬប្រពន្ធ)ពិការធ្ងន់ធ្ងរឬមានជំងឺរ៉ាំរ៉ៃ គ្រួសារដែលមានសមាជិកសុទ្ធតែចាស់ជរា គ្រួសារដែលមានកុមារកំព្រារស់នៅជាមួយ គ្រួសារដែលមានមេគ្រួសារជាស្ត្រីមេម៉ាយមានកូនតូចៗច្រើន ឬគ្រួសារគ្មានកម្លាំងពលកម្ម
- ស្ថានភាពដែលធ្វើឲ្យជីវភាពគ្រួសារប្រសើរឡើងដូចជា ជំនួយពីសាច់ញាតិឬប្រភពផ្សេងទៀត។

ការកែសម្រួលបញ្ជីសំណួរនិងការផ្សព្វផ្សាយសាជាថ្មី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងផែនការ។

## ជំពូកទី៤
## ការគ្រប់គ្រងនិងការប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រ

**មាត្រា ១៤.-**

ក្រសួងផែនការមានសមត្ថកិច្ចគ្រប់គ្រងទិន្នន័យគ្រួសារក្រីក្រដែលបានមកពីលទ្ធផលនៃការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រថ្នាក់ជាតិ។

**មាត្រា ១៥.-**

ក្រសួងផែនការមានភារកិច្ចគ្រប់គ្រងការបញ្ចូល ការផ្តុំ ការកែច្នៃ ការវិភាគ ការចងក្រង ការរក្សាទុក និងការផ្សព្វផ្សាយរាល់ទិន្នន័យគ្រួសារក្រីក្រដែលបានប្រមូលតាមរយៈនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

ក្រសួងផែនការ ជាស្ថាប័នតែមួយគត់ដែលមានសិទ្ធិផ្សព្វផ្សាយនិងចែកចាយជាលើកដំបូងនូវទិន្នន័យចេញពីមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រ។

**មាត្រា ១៦.-**

ក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន មានសិទ្ធិទទួលនិងប្រើប្រាស់ទិន្នន័យចេញពីមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រថ្នាក់ជាតិនៃក្រសួងផែនការ។ រាល់ការប្រើប្រាស់និងការចែកចាយបន្តនូវទិន្នន័យគ្រួសារក្រីក្រដោយផ្នែកឬទាំងស្រុង ត្រូវធ្វើឡើងដោយឥតគិតថ្លៃនិងក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រនិងបម្រើឲ្យផលប្រយោជន៍សង្គមតែប៉ុណ្ណោះ។

**មាត្រា ១៧.-**

ក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន ដែលមានបំណងផ្តល់សេវាឬជំនួយដល់គ្រួសារឬជនក្រីក្រ រួមទាំងអន្តរាគមន៍បន្ទាន់ទាំងឡាយណាដែលសមស្រប ត្រូវប្រើប្រាស់ជាចម្បងនូវទិន្នន័យគ្រួសារក្រីក្រថ្នាក់ជាតិដែលមានសុពលភាព។

**មាត្រា ១៨.-**

ទិន្នន័យគ្រួសារក្រីក្រនៃភូមិណាមួយ នៅមានសុពលភាពរហូតដល់ក្រសួងផែនការចេញផ្សាយទិន្នន័យថ្មីដែលបានធ្វើបច្ចុប្បន្នកម្ម។ ក្នុងករណីដែលភូមិណាមួយមិនបានធ្វើបច្ចុប្បន្នកម្មទេនោះ ទិន្នន័យមានសុពលភាពត្រឹមរយៈពេលបួនឆ្នាំ បន្ទាប់ពីការបញ្ជាក់ទទួលស្គាល់បញ្ជីគ្រួសារក្រីក្រដោយមេឃុំ ចៅសង្កាត់ បន្ទាប់ពីការសម្រេចរបស់ក្រុមប្រឹក្សាឃុំសង្កាត់។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា ១៩.-**

ប្រភពធនធានសម្រាប់ដំណើរការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ បានមកពីថវិកាជាតិដែលជាកញ្ចប់ថវិការបស់ក្រសួងផែនការ ដៃគូអភិវឌ្ឍ និងប្រភពផ្សេងទៀត។

## ជំពូកទី៦
## វិធានការរដ្ឋបាល

**មាត្រា ២០.-**

ក្នុងករណីដែលក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋានណាមួយ ធ្វើសកម្មភាពដែលរំលោភលើបញ្ញត្តិនៃអនុក្រឹត្យនេះ ក្រសួងផែនការមានសិទ្ធិបញ្ជាឲ្យបញ្ឈប់សកម្មភាពនោះជាបន្ទាន់ ហើយក្នុងករណីចាំបាច់ ក្រសួងអាចបដិសេធការទទួលស្គាល់ព័ត៌មាន និងទិន្នន័យដែលទទួលបានពីការអនុវត្តសកម្មភាពនោះ។

**មាត្រា ២១.-**

ជនណាក្លែងបន្លំទិន្នន័យដែលបានមកពីការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា ២២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ